# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៥៥៣៧ ព.ណ.ត.ល.ប.

ថ្ងៃ៦ ០៥កើត ខែ ពិសាខ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ៤ ឆ្នាំ ២០១៨

**<u>ជម្រាបមក</u>**

**លោក/លោកស្រីប្រធានក្រុមហ៊ុន មហោសថ ពាណិជ្ជ**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្ដាច់មុខលើផលិតផលម្សៅម៉ដ្ឋ សាប៊ូដុំ ថ្នាំដុសធ្មេញ សាប៊ូកក់សក់ និងផលិតផលលាងសម្អាតម៉ាក "IODERM" ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **មហោសថ ពាណិជ្ជ**។

**យោង:** - មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **មហោសថ ពាណិជ្ជ** ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៧
- លិខិតប្រគល់សិទ្ធិផ្ដាច់មុខរបស់ក្រុមហ៊ុន SAHAPHAN GROUP (THAILAND) CO., LTD ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៧
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/២៤៥៦/៩៤ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្ដាច់មុខលើផលិតផលម្សៅម៉ដ្ឋ សាប៊ូដុំ ថ្នាំដុសធ្មេញ សាប៊ូកក់សក់ និងផលិតផលលាងសម្អាតពាក់ម៉ាកខាងលើក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **មហោសថ ពាណិជ្ជ** ដែលទទួលបានពីក្រុមហ៊ុន SAHAPHAN GROUP (THAILAND) CO., LTD ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និង ចែកចាយផ្ដាច់មុខ ដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខ មានសុពលភាពរយៈពេល ០២(ពីរ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន SAHAPHAN GROUP (THAILAND) CO., LTD ដែលជាម្ចាស់ម៉ាក ។

ចាប់ពីរយៈពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខ អ្នកទទួលសិទ្ធិស្របច្បាប់ មានសិទ្ធិប្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងចំពោះទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្ដាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្ត ជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

អ៊ុក ប្រជា

<u>*ចម្លងជូន:*</u>
- *ខុទ្ទកាល័យ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន***
- *ខុទ្ទកាល័យ សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ ឯកឧត្ដម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ*
- *ខុទ្ទកាល័យឯកឧត្ដមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *អគ្គនាយកដ្ឋានកាំកុងត្រូល*
- *អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារ: (៨៥៥) -២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*